EXCEL

Newsletter ព្រឹត្តប័ត្រព័ត៌មាន អិចសែល

April – June 2014
Year 1 – No. 01

*ទាំងអស់គ្នា ជាដៃគូក្នុងការលុបបំបាត់ពលកម្មកុមារ*
*Together we partner for the elimination of Child Labor*

*មេសា-មិថុនា ២០១៤*
*ឆ្នាំទី១ - លេខ: ០១*

## សាវតារគម្រោងអិចសែល (EXCEL)

គម្រោងរបស់អង្គការទស្សនៈពិភពលោក: "ការលុបបំបាត់នូវការកេងប្រវ័ញ្ចពលកម្មកុមារនៅកម្ពុជាតាមរយៈការផ្តល់ការសិក្សាអប់រំនិងការគាំទ្រការលើកកម្ពស់ជីវភាព (EXCEL)" នៅប្រទេសកម្ពុជា បានទទួលការឧបត្ថម្ភថវិកាសរុប ចំនួន១១លានដុល្លារអាមេរិក ពីក្រសួងការងារសហរដ្ឋអាមេរិក USDOL ($ ១០លាន) និង អង្គការ World Vision អាមេរិក ($១លាន) សម្រាប់រយៈពេល៤ឆ្នាំ ពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ អនុស្សារណៈយោគយល់គ្នានៃគម្រោងនេះត្រូវបានចុះហត្ថលេខាជាផ្លូវការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ និងជាមួយក្រសួងអប់រំ យុវជននិងកីឡា នៅថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៣។

គម្រោង EXCEL មានបំណងកាត់បន្ថយការកេងប្រវ័ញ្ចពលកម្មកុមារនៅក្នុងផ្នែកនេសាទ កសិកម្ម និងសេវាបម្រើតាមផ្ទះនៅក្នុងប្រទេសកម្ពុជា ដោយអនុវត្តវិធីសាស្ត្រពហុវិស័យតាមរយៈការផ្តល់សេវាអប់រំនិងការទ្រទ្រង់ជីវភាពដោយផ្ទាល់ និងការបង្កើតបណ្តាញសម្រាប់កុមារគោលដៅអាយុពី៥ដល់១៧ឆ្នាំចំនួន២៨០០០នាក់ និង ១៤០០០គ្រួសារ និងតាមរយៈការតស៊ូមតិនិងការលើកកម្ពស់ការយល់ដឹងពីពលកម្មកុមារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

គម្រោងនេះត្រូវបានអនុវត្តដោយអង្គការទស្សនៈពិភពលោកកម្ពុជា ក្នុងភាពជាដៃគូជាមួយអង្គការ Wathanakpheap (WP) អង្គការគាំពារកុមារងាយរងគ្រោះ VCAO) អង្គការអភិវឌ្ឍន៍ជីវភាពកសិករ (FLD) និងវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) គ្របដណ្តប់លើខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ពោធិសាត់ កំពង់ចាម និង រាជធានីភ្នំពេញ។



*ខ្លឹមសារនៅក្នុងព្រឹត្តប័ត្រព័ត៌មាននេះមិនឆ្លុះបញ្ចាំងពីទស្សនៈឬគោលនយោបាយរបស់ក្រសួងការងារសហរដ្ឋអាមេរិកឡើយ ហើយការបរិយាយទាក់ទងនឹងឈ្មោះពាណិជ្ជកម្ម ផលិតផលពាណិជ្ជកម្ម ឬអង្គភាពនានាក៏មិនមានន័យថាទទួលបាន ការអនុម័តពីរដ្ឋាភិបាលសហរដ្ឋអាមេរិកដែរ។*

គម្រោងលុបបំបាត់ពលកម្មកុមារតាមរយៈការអប់រំនិងការលើកកម្ពស់ជីវភាព(EXCEL)

*គម្រោងនេះទទួលបានមូលនិធិពីក្រសួងការងារសហរដ្ឋអាមេរិក (USDOL)*




*សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំគោលការណ៍ណែនាំអំពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យជលផល, ថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០១៤ នៅខេត្តសៀមរាប*




*ឯកឧត្តម ណៅ ធូក អគ្គនាយក រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខា និង នេសាទ ថ្លែងសន្ទរកថាក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំគោលការណ៍ណែនាំអំពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យជលផល, ថ្ងៃទី ១៤ខែមិនាឆ្នាំ២០១៤ នៅខេត្តសៀមរាប*

## **គោលការណ៍ណែនាំ** ស្តីអំពីពលកម្មកុមារក្នុងវិស័យនេសាទ នៅកម្ពុជាបោះជំហានទៅមុខ

គម្រោងអិចសែលបានផ្តួចផ្តើមនិងគាំទ្រការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដើម្បីបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យនេសាទ។ សិក្ខាសាលានេះត្រូវបានរៀបចំ ឡើងដោយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានការងារកុមារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សិក្ខាសាលានេះបានរៀបចំ បន្តពីសិក្ខាសាលាថ្នាក់ខេត្តដែលបានធ្វើកាលពីពេលមុននៅក្នុងខេត្តពោធិសាត់ និងខេត្តសៀមរាប ដែលគម្រោងអិចសែលបានសម្របសម្រួលរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំថ្នាក់ជាតិ ជាមួយអ្នកពាក់ព័ន្ធនានា។ សិក្ខាសាលានេះមានការចូលរួមពីតំណាងរបស់រដ្ឋាភិបាល សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន សហជីព និយោជក និងអង្គការដៃគូនានា។

ឯកឧត្តម **ណៅ ធូក** អគ្គនាយករដ្ឋបាលជលផល បានមានប្រសាសន៍នៅក្នុងអង្គសិក្ខាសាលាថាៈ វិស័យនេសាទពិតជាត្រូវការចាំបាច់នូវគោលការណ៍ណែនាំទាក់ទងនឹងពលករករកុមារទាំងនេះ។ លោកបានមានប្រសាសន៍គាំទ្រគំនិតផ្តួចផ្តើមនេះថា"ខណៈដែលពលកម្មកុមារនៅក្នុងឧស្សាហកម្មនេសាទត្រូវបានគេរកឃើញថាមានផលប៉ះពាល់ខ្ពស់ដល់ការអភិវឌ្ឍន៍ផ្នែករាងកាយនិងស្មារតីរបស់កុមារ.....យើងបានកត់សំគាល់ថាពុំទាន់មានគោលការណ៍ណែនាំ ឫប្រកាសណាមួយជាក់លាក់និងអាចអនុវត្តបាននៅក្នុងវិស័យនេះនៅឡើយ។"

គេរំពឹងថា គោលការណ៍ណែនាំដែលនឹងត្រូវអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអាចជួយកាត់បន្ថយបញ្ហាពលកម្មកុមារនៅក្នុងប្រទេសកម្ពុជាបន្ថែមទៅលើគោលការណ៍ពលកម្មកុមារដែលមានស្រាប់។ ទាំងអង្គការកសិកម្ម និងស្បៀងអាហារសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ បានពិនិត្យគោលការណ៍ណែនាំនេះ និងបានផ្តល់ជំនួយបច្ចេកទេស ដល់រដ្ឋបាលជលផលដើម្បីគាំទ្រគម្រោងនេះ។ ដំណើរការនៃការអនុម័តសេចក្តីព្រាងគោលការណ៍ណែនាំនេះនឹងចំណាយពេលពី ៦ ខែ ទៅ១២ ខែ ហើយគម្រោងអិចសែលនឹងធ្វើសកម្មភាពគាំទ្រផ្សព្វផ្សាយ បន្ទាប់ពីអនុម័តរួច។

## គម្រោង EXCEL ស្វែងរកការគាំទ្រឲ្យមានការចាត់ចែងធានការបន្ទាន់ប្រឆាំងនឹងពលកម្មកុមារ

ចាប់តាំងពីឆ្នាំ២០០២ គេសង្កេតឃើញទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា ដោយរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារសហប្រជាជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ និងគៀងគរអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីចាត់វិធានការជាបន្ទាន់ប្រឆាំងពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

កម្មវិធីទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារឆ្នាំ២០១៤ បានគូសបញ្ជាក់ពីតួនាទីនៃកិច្ចគាំពារសង្គមក្នុងការទប់ស្កាត់កុមារកុំឲ្យធ្លាក់ចូលក្នុងពលកម្មកុមារ និងរំដោះពួកគេឲ្យរួចផុតពីការកេងប្រវ័ញ្ចពលកម្ម។ ឆ្នាំនេះរាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំទូទាំងប្រទេសជំរុញឲ្យស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍ចូលរួមប្រារព្ធទិវាកុមារអន្តរជាតិលើកទី៦៤ នៅថ្ងៃទី ០១ មិថុនា ក្រោមប្រធានបទ " **រួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ**" និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារលើកទី១៣ នៅថ្ងៃទី១២ ខែមិថុនា ក្រោមប្រធានបទ "**ពង្រីកកិច្ចគាំពារសង្គម ប្រឆាំងនឹងពលកម្មកុមារ**"។ (តទៅទំព័រទី៣)

រួមចំណែកក្នុងការប្រារព្ធទិវានេះ គម្រោងបានគាំទ្រសកម្មភាពជាច្រើន នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគមន៍ ដោយសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(CNCC) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលទទួលសិទ្ធិកុមារ មន្ទីរពាក់ព័ន្ធនៅតាមខេត្តគោលដៅការិយាល័យអប់រំស្រុក អាជ្ញាធរមូលដ្ឋាន និងដៃគូអង្គការក្រៅរដ្ឋាភិបាលនានា។




## សកម្មភាពនៅថ្នាក់ជាតិ

ការប្រារព្ធទិវាកុមារអន្តរជាតិនិងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ នៅថ្នាក់ជាតិត្រូវបានប្រារព្ធឡើងនៅថ្ងៃទី១មិថុនា នៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ ដោយមានការចូលរួមគាំទ្រពីគម្រោងមួយចំនួនដូចជា EXCEL, MCCP, គម្រោងកុមារតូច និងអង្គការដៃគូអនុវត្តគម្រោងEXCEL។ ទិវានេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវឧបនាយករដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល តំណាងស្ថានទូតនានា អ្នកការទូត ភ្ញៀវអន្តរជាតិ អង្គការសង្គមស៊ីវិល គ្រូបង្រៀន អាជ្ញាធរមូលដ្ឋាន និងកុមារសរុបចំនួនជាង ២៥០០ នាក់។

វេទិកាកុមារតាមទូរទស្សន៍ក៏ត្រូវបានធ្វើឡើងនៅថ្ងៃទី២៤ ឧសភា ដែលមានកុមារចូលរួមប្រមាណ២៥០នាក់មកពីសាលានានានិងវាគ្មិនត្តិយស៩រូបមកពីក្រសួងការងារ ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច ក្រសួងមហាផ្ទៃ គណៈកម្មាធិការ អង្គការក្រៅរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិកុមារ តំណាងយុវជនជាតិស្វែងរកការគាំទ្រមតិហើយក្រុមការងារគម្រោងEXCEL ក៏ត្រូវបានអញ្ជើញក្នុងកម្មវិធីសំណួរចម្លើយទាក់ទងនឹងការការពារកុមារ ពលកម្មកុមារ ការអប់រំកុមារ ការរំលោភបំពានលើសិទ្ធិកុមារ។ វេទិកាកុមារនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយទូរទស្សន៏ជាតិកម្ពុជាក្នុងប្រទេសកម្ពុជា និងប្រទេសមួយចំនួនក្នុងទ្វីបអឺរ៉ុប និងទ្វីបអាមេរិក។

ការសំដែងឆាកកំប្លែងតាមទូរទស្សន៍ CTN ដែលមានសារទាក់ទងនឹងពលកម្មកុមារ កុមារបម្រើការងារតាមផ្ទះ និងការលើកកម្ពស់ការអប់រំសម្រាប់កុមារត្រូវបានផ្សាយជាបន្តបន្ទាប់នៅថ្ងៃទី២៤, ទី៣១ ខែឧសភា ឆ្នាំ២០១៤ និងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១៤។

## សកម្មភាពនៅថ្នាក់ក្រោមជាតិ និងសហគមន៍

សកម្មភាពនានាត្រូវបានធ្វើឡើងនៅថ្នាក់ក្រោមជាតិ និងសហគមន៍ តាមរយៈការជួយគាំទ្រពីគម្រោង និងអង្គការដៃគូនានាសហការជាមួយមន្ត្រីថ្នាក់ខេត្ត ជាពិសេសមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ការិយាល័យអប់រំស្រុក អាជ្ញាធរមូលដ្ឋាន និងសាលារៀន។ ពិធីទាំងនេះត្រូវបានប្រារព្ធឡើងនៅ ៣៣ កន្លែងនៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប កំពង់ចាម ពោធិសាត់ និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ២០៤២៧ នាក់ រួមមានកុមារ គ្រូបង្រៀន នាយកសាលា អាជ្ញាធរមូលដ្ឋាន និងសហគមន៍។

ពិធីទាំងនោះ ប្រព្រឹត្តទៅក្រោមអធិបតីភាពអភិបាលរងខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប។ សកម្មភាពផ្សេងៗត្រូវបានរៀបចំឡើងនៅក្នុងទិវាទាំងនេះដើម្បីជំរុញឲ្យមានការចូលរួមយ៉ាងសកម្ម ដូចជាកម្មវិធីសំណួរ-ចម្លើយ វេទិកាសហគម ឆាកកំប្លែង ដែលមានសារលើកកម្ពស់ការយល់ដឹងពីការការពារសិទ្ធិកុមារ បញ្ហាពលកម្មកុមារ និងការជួញដូរកុមារ។





## ការប្រារព្ធទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ នៅរាជធានីភ្នំពេញ

*"ខ្ញុំនឹងបង្កើតមុខរបរផ្ទាល់ខ្លួនមួយដើម្បីទ្រទ្រង់ជីវភាព និងកសាងអនាគតរបស់ខ្ញុំឲ្យភ្លឺថ្លា ដោយប្រើប្រាស់ជំនាញដែលខ្ញុំបានទទួលពីមជ្ឈមណ្ឌលរបស់អង្គការ VCAO"* នេះជាសំដីរបស់កញ្ញា សំណាង អាយុ១៦ឆ្នាំ ជាកុមារបំរើការងារតាមផ្ទះដែលបានថ្លែងក្នុង **ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ** ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ រៀបចំដោយអង្គការ VCAO ។

ទិវានេះត្រូវបានប្រារព្ធឡើង ដោយមានកិច្ចសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងស្តារនីតិសម្បទារាជធានីភ្នំពេញ នៅមជ្ឈមណ្ឌលកូឡាបទីIV របស់ អង្គការ VCAO ក្រោមអធិបតីភាពលោក ស្រី **មុំ ចាន់ដានី** អនុប្រធានគណៈកម្មការទទួលបន្ទុកស្រីនិងកុមារ រាជធានីភ្នំពេញ និងជាអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងស្តារនីតិ សម្បទារាជធានីភ្នំពេញ និងលោក **ជួន វុទ្ធី** អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ ព្រមទាំងមានការចូលរួមជាកិត្តិយសពីលោកស្រី **ញ៉ែម មុំ** ប្រធានគណៈកម្មការស្រី និងកុមារ ខណ្ឌទួលគោក និងលោក ជា ពីដែន នាយកប្រតិបត្តិអង្គការVCAO ។

អ្នកចូលរួមសរុបមានចំនួន ២២០ នាក់ រួមមានប្រធានការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រុមប្រឹក្សាសង្កាត់នានា សិក្ខាកាមដែលបានបញ្ចប់វគ្គសិក្សានៅអង្គការ VCAO កុមារបម្រើការងារតាមផ្ទះ និងកុមារដទៃទៀត។ គោលបំណងនៃទិវានេះ គឺដើម្បីពង្រឹកកិច្ចគាំពារសង្គមសម្រាប់កុមារ និងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ជាពិសេសកុមារបម្រើការងារតាមផ្ទះ(តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទុនមុខរបរសម្រាប់អាជីវកម្មខ្នាតតូច ព្រមទាំងចែកវិញ្ញបនប័ត្របញ្ចប់ការសិក្សាដល់សិក្ខាកាមដែលបានបញ្ចប់វគ្គសិក្សា។







## ក្ដីសង្ឃឹមថ្មីរបស់កុមារី ទី



**ទី** ពេលទៅនេសាទជាមួយឪពុក



ទី (រូបស្ដាំ)និង ប្អូនស្រីរបស់នាង(រូបឆ្វេង) ទៅសាលាក្រោយទទួលបានការគាំទ្រអាហាររូបករណ៍ពីគម្រោង

ទី និយាយថា *"ថ្ងៃអនាគត ខ្ញុំចង់ធ្វើជា គ្រូបង្រៀនដ៏ល្អម្នាក់ក្នុងភូមិ"*

***យើងសូមបួងសួងឲ្យសេចក្ដីប្រាថ្នារបស់នាងបានសម្រេចដូចបំណង***

កុមារី ទី មានអាយុ១១ឆ្នាំ ជាកូនម្នាក់ក្នុងចំណោមកូនទាំង៨របស់គ្រួសារដ៏ក្រីក្រមួយ រស់នៅក្នុងសាលាឆទានស្ថិតក្នុងភូមិក្រមុល ឃុំរហាត់ទឹក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ ទី តែងតែទៅនេសាទជាមួយឪពុករបស់នាង ឈ្មោះ ប៉ូ ង៉ិ អាយុ៤៥ឆ្នាំ។ ម្ដាយរបស់នាងឈ្មោះ ដូក ទឹម អាយុ ៤២ឆ្នាំ នៅផ្ទះមើលថែទាំកូននិងគ្រួសារទាំងមូល។ គ្រួសារនេះមានកូន១០នាក់ ប៉ុន្តែកូនម្នាក់បានស្លាប់ ដោយសារជម្ងឺគ្រុនឈាម និងកូនម្នាក់ទៀតស្លាប់ដោយសារលង់ទឹក។

មិនមែនការសរសេរឡើយ ប៉ុន្តែគឺជាការអុំទូកទៅវិញទៅមកដែលជាជំនាញរបស់ ទី ក្រៅពីការបេះត្រកួន ផ្កាឈូក និងប្រមូលអនុផលព្រៃឈើ។ នាងចំណាយពេលជាច្រើនម៉ោងនៅក្នុងទឹក និងអុំទូកពីកន្លែងមួយទៅកន្លែងមួយ ហើយនាងមិនដែលបានចូលសាលារៀនឡើយ។

ដោយមានការជួយគាំទ្រពីគម្រោង អិចសែលសហការជាមួយអាជ្ញាធរមូលដ្ឋាន និងនាយកសាលាបឋមសិក្សារហាត់ទឹក ទី និងប្អូនស្រី របស់ នាង វ៉ាន់ឌី បច្ចុប្បន្នកំពុងរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សារហាត់ទឹក។ ពួកគេទទួលបានកង់មួយ សំលៀកបំពាក់ សំពៀត សៀវភៅ ប៊ិច និងខ្មៅដៃ។ នាងនិងប្អូនស្រីសប្បាយចិត្តណាស់ដែលបានចូលរៀន។

## ក្រុមការងារអប់រំសម្រាប់គម្រោង EXCEL

គម្រោងEXCEL សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រដ៏សកម្មរបស់ក្រសួងអប់រំយុវជននិងកីឡា។ ក្រុមការងារEXCELត្រូវបានអនុញ្ញាតឱ្យចូលជួបសំដែងការគួរសមជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា **ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន** នៅដើមឆ្នាំ ២០១៤ ។ បន្ទាប់ពីបានទទួលអនុសាសន៍ស្តីពីការបង្កើតក្រុមការងារផ្នែកអប់រំគម្រោង EXCEL តាមរយៈការជួបសំដែងការគួរសមនោះ កិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ត្រូវបានធ្វើឡើងជាមួយ **ឯកឧត្តម សំ សេរីរតន៍** អគ្គនាយកអប់រំ និងជាមួយនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីបន្តធ្វើកិច្ចការនេះ។

ដោយមានការជួយគាំទ្រពីនាយកដ្ឋានបឋមសិក្សា ក្រុមការងារអប់រំគម្រោង EXCEL ត្រូវបានបង្កើតឡើងជាផ្លូវការ នៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤។ ក្រុមការងារនេះមានគណៈកម្មការពីរ គណៈកម្មការប្រឹក្សាគម្រោងផ្នែកអប់រំ និងគណៈកម្មការបច្ចេកទេសគម្រោងផ្នែកអប់រំ ដែលមានសមាសភាពថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអប់រំ ថ្នាក់ដឹកនាំអង្គការដៃគូ និងសមាជិកគម្រោង EXCEL។

ក្រុមការងារអប់រំនេះ មានតួនាទីផ្តល់ការគាំទ្រ និងផ្តល់អនុសាសន៍ស្តីពីការអនុវត្តគម្រោងEXCEL។ គោលបំណងនៃការបង្កើតក្រុមការងារនេះ គឺដើម្បីធានាថាគម្រោង EXCEL ត្រូវបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការល្អ ជាមួយក្រសួងអប់រំទាំងនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំជាលើកដំបូងរបស់គណៈកម្មការបច្ចេកទេសអប់រំ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី៧ ខែកក្កដាឆ្នាំ២០១៤ ក្នុងស្នារតីទទួលខុសត្រូវខ្ពស់ ។



ការប្រជុំក្រុមការងារអប់រំលើកទី១
ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤



សិស្សានុសិស្សអានសៀវភៅក្នុងបណ្ណាល័យសាលារៀនមួយ ក្នុងខេត្តបាត់ដំបង

## សមិទ្ធផលសំខាន់ៗ របស់គម្រោងកន្លងមក

### ផ្នែកអប់រំ

- ការផ្តល់សម្ភារៈបង្រៀននិងការរៀន : ផ្ទាំងរូបភាព ជញ្ជីង វចនានុក្រម សៀវភៅអាន អក្សរចល័ត កូគោល និងបរិក្ខារផ្សេងទៀត ជូនសាលារៀន គោលដៅចំនួន ៦២សាលា ។
- ការផ្តល់អាហារូបករណ៍ដល់កុមារ: ឯកសណ្ឋាន សំពៀត សៀវភៅ ប៊ិច ខ្មៅដៃ, ជ័រលុប បន្ទាត់ និងស្បែកជើង ដល់កុមារសរុបចំនួន ៤៩៥៧ កុមារ (ស្រី២៤៨៧ នាក់)។
- ការផ្តល់កង់: ចំនួន ៥១៨ គ្រឿង ដល់ កុមារ៥១៨ នាក់ (ស្រី ២៥៥ នាក់)
- ការបណ្តុះបណ្តាលគ្រូ: ចំនួន១៥៨(ស្រី៧២នាក់)
- ថ្នាក់បំប៉ន: ១៥៩៣ កុមារ ( ស្រី ៥៦៤ នាក់)
- ផែនទីខ្នងផ្ទះ: សាលារៀនចំនួន ៣៩
- យុទ្ធនាការចុះឈ្មោះចូលរៀន: ១៤ សាលារៀន
- ជួលជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន: ៣៨សាលារៀន

### ការលើកកម្ពស់ជីវភាពរស់នៅ

- បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម: ៨០៤ គ្រួសារនិងយុវជន ៧៩នាក់និង ផ្តល់ទុនមុខរបរដល់ ៣៤៣ គ្រួសារ និងយុវជនចំនួន៤១ (ការចិញ្ចឹម មាន់ ជ្រូក ត្រី)
- បណ្តុះបណ្តាលមិនមែនកសិកម្ម: ២៥គ្រួសារ (កាត់ដេរ, តន្ត្រីបុរាណខ្មែរ ... )
- ការបង្កើតក្រុមសន្សំ : ២៤ក្រុមសន្សំ
- បណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជន: ១៤៦ នាក់។

### ការស្វែងរកការគាំទ្រមតិ

- ការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិ: កំពុងដំណើរការបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល។
- គាំទ្រក្រុមប្រឹក្សាឃុំសង្កាត់: ២៦ ឃុំ / សង្កាត់ ដើម្បីបញ្ជ្រាបបញ្ហាពលកម្មកុមារ។
- ការបង្កើតក្លឹបកុមារ / យុវជន : ៣៨ ក្លឹប
- កម្មវិធីវិទ្យុនិងទូរទស្សន៍: រឿងអប់រំចំនួន២រឿង ឈុតផ្សព្វផ្សាយតាមវិទ្យុចំនួន៤ និងកម្មវិធីវិទ្យុស្តីពីពលកម្មកុមារចំនួន១៤កម្មវិធី ផ្សាយតាមវិទ្យុសារិកា។
- ផលិតសម្ភារលើកកម្ពស់ការយល់ដឹង: ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូ និងសម្ភារផ្សព្វផ្សាយ ស្តីពីពលកម្មកុមារក្នុងគ្រប់ទម្រង់ជាខិត្តប័ណ្ណ ប័ណ្ណផ្ទត់ ផ្ទាំងរូបភាពនិងកូនសៀវភៅអំពីប្រកាសស្តីពីពលកម្ម កុមារនិងអនុសញ្ញា C138 និង C182។
- យុទ្ធនាការមហាជន: ប្រារព្ធទិវាកុមារអន្តរជាតិ ០១ មិថុនានិងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ ខែមិថុនានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅ ៣៣ កន្លែង មានអ្នកចូលរួមប្រមាណ ២០២៤៧ នាក់ និង រៀបចំវេទិកាកុមារនៅលើកញ្ចក់ទូរទស្សន៍ ទទក។

### ការស្រាវជ្រាវ

- ការស្រាវជ្រាវ អំពីកុមារបម្រើការងារតាមផ្ទះ: ការស្ទង់មតិជាមួយ១០៧១គ្រួសារបានបញ្ចប់និងកំពុងរៀបចំរបាយការណ៍ស្រាវជ្រាវចុងក្រោយ។

# សកម្មភាពសំខាន់ៗ

## នៅត្រីមាសបន្ទាប់

- ផ្តល់អាហារូបករណ៍ដល់កុមារប្រមាណ ១២០០០ នាក់។
- រៀបចំថ្នាក់បំប៉នដល់កុមារប្រមាណ២០០០នាក់។
- ផ្តល់កង់ចំនួន ២១២គ្រឿងដល់កុមារ។
- ផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្មនិងវិជ្ជាជីវៈនិងផ្តល់ទុនមុខរបរគ្រួសារ និងយុវជនគោលដៅ។
- រៀបចំជាក្រុមសន្សំសម្រាប់គ្រួសារ និងយុវជនគោលដៅ។
- រកការងារឲ្យយុវជនតាមកន្លែងធ្វើអាជីវកម្ម និងកន្លែងហាត់ការនានា។
- ផលិតកម្មវិធីទូរទស្សន៍ ស្តីពីពលកម្មកុមារ ផ្សាយរៀងរាល់ពីរសប្តាហ៍ម្តង និងចាក់ផ្សាយឡើងវិញពីរដងក្នុងមួយខែ សម្រាប់រយៈពេល១២ខែ។
- ផលិតកម្មវិធីវិទ្យុ ស្តីពីពលកម្មកុមារ ផ្សាយរៀងរាល់ពីរសប្តាហ៍ម្តង និងចាក់ផ្សាយឡើងវិញពីរដងក្នុងមួយខែ សម្រាប់រយៈពេល១២ខែ។
- បញ្ចប់ឯកសារគោលការណ៍ណែនាំ ស្តីពីពលកម្មកុមារក្នុងវិស័យជលផល។








ទំនាក់ទំនងព័ត៌មានៈ

**Ms. Imelda Ochavillo,** Project Director, EXCEL Project, WVC.

Email: Imelda_ochavillo@wvi.org

#20, Street 71, Tonle Basac, Chamkar Morn, Phnom Penh. PO Box 479.

www.worldvision.org.kh